**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩៩៨ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម

# ស្តីពី

# ការផ្តល់រង្វាន់លើកទឹកចិត្តជូន

# ក្រសួងទេសចរណ៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ៩៩៧ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

## ស ម្រេ ច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀតលើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ ៣** :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ៩៩៧ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានីខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងទេសចរណ៍ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤** :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ចំពោះចំណូលពីអាជ្ញាប័ណ្ណទេសចរណ៍ ៖

ក១. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងទេសចរណ៍ ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន

ក២. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរទេសចរណ៍រាជធានី ខេត្ត ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលដែលប្រមូលបាន

ខ. ចំពោះចំណូលពីការផាកពិន័យអន្តរការណ៍ ៖

ខ១. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងទេសចរណ៍ ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន

ខ២. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរទេសចរណ៍រាជធានី ខេត្ត ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលដែលប្រមូលបាន

**ប្រការ ៥** :

រដ្ឋបាលកណ្តាលនៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងទេសចរណ៍ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទាន

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងទេសចរណ៍ដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងទេសចរណ៍ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិមកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីរទេសចរណ៍រាជធានី ខេត្តត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៦** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

VK

**ប្រការ ៧ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង-ខុន**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»

- [illegible]